ជស/រកម/ ០៨៩៩/០៩

# ព្រះរាជក្រម

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

---

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានទ្រង់យល់សម័យប្រជុំវិសាមញ្ញពេញអង្គនៃរដ្ឋសភានីតិកាលទី២ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩
- បានទ្រង់យល់សម័យប្រជុំវិសាមញ្ញពេញអង្គនៃព្រឹទ្ធសភានីតិកាលទី១ ថ្ងៃទី១៧ខែសីហាឆ្នាំ១៩៩៩
- បានទ្រង់យល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ០១៣ កបធ.សសរ.ច ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៩
- យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្ដីទី ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៩

## ត្រាស់បង្គាប់

<u>មាត្រា ១</u> : ប្រកាសឱ្យប្រើជាផ្លូវការនូវ ច្បាប់ស្ដីពីរយៈពេលនៃការឃុំខ្លួនជាបណ្ដោះអាសន្ន ។

<u>មាត្រា ២</u> : ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៩

ជំនួសព្រះបរមនាមនិង តាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ជា ស៊ីម

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

## ច្បាប់

## ស្ដីពី

## រយៈពេលនៃការឃុំខ្លួនជាបណ្ដោះអាសន្ន

**មាត្រា ១.-**

រយៈពេលនៃការឃុំខ្លួនជាបណ្ដោះអាសន្ន ទោះស្ថិតក្នុងករណីណាក៏ដោយមិនត្រូវឱ្យហួសពីបួនខែទេ ។ ប៉ុន្តែតាមការសំរេចរបស់ចៅក្រមដែលមានមូលហេតុច្បាស់លាស់ រយៈពេលនេះអាចបន្តដល់ប្រាំមួយខែបាន ប្រសិនបើមានការចាំបាច់សំរាប់ធ្វើការស៊ើបអង្កេត ។

ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាមនិងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងអនុសញ្ញានានារបស់អង្គការសហប្រជាជាតិដែលកម្ពុជាជាហត្ថលេខី ការឃុំខ្លួនជាបណ្ដោះអាសន្នខាងលើនេះ អាចពន្យាររយៈពេលមួយឆ្នាំម្ដងៗ ប៉ុន្តែរយៈពេលនៃការពន្យារនេះ មិនត្រូវឱ្យលើសពីបីឆ្នាំឡើយ ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ២ ។

ភ្នំពេញ,ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៩

ប្រធានរដ្ឋសភា

នរោត្តម រណឫទ្ធិ